ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ២៦២៧ សនល.អក.អឞ

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ថែទាំ និងផ្លាស់ប្តូរបរិក្ខារប្រព័ន្ធបណ្តាញចែកចាយ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដោយមូលហេតុដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី១៣ ខែមីនា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១២ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិចំការឪឡឹក ក្នុងសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ និង (២)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៦ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិទួលសង្កែ ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

២. ថ្ងៃសុក្រទី១៤ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅ (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិព្រៃព្រីងខាងត្បូង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិអង្គកែវ ភូមិកន្ទោក ភូមិអង្គ ក្នុងសង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

៣.ថ្ងៃសៅរ៍ទី១៥ ខែមីនា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១២ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិដំណាក់ធំ៣ ភូមិទ្រា៤ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ និង (២)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៦ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិត្រពាំងថ្លឹង ភូមិថ្មគោល ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

៤. ថ្ងៃអាទិត្យទី១៦ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៦ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅ (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ២ ចាប់ពីសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ រហូតដល់ឃុំព្រែកហូរ ក្នុងស្រុកតាខ្មៅ ខេត្តកណ្តាល និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវចំការដូង ចាប់ពីភូមិម័ល រហូតដល់ភូមិបាគូ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីកែលម្អខ្សែបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

៥. ថ្ងៃសៅរ៍ទី១៥ និងថ្ងៃអាទិត្យទី១៦ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅ (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ6A ចាប់ពីសង្កាត់ជ្រោយចង្វារ រហូតដល់សង្កាត់ព្រែកលាប ក្នុងខណ្ឌឫស្សីកែវ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ ចាប់ពីភូមិផ្សារលិច រហូតដល់ភូមិខ្នង ក្នុងសង្កាត់ព្រែកព្នៅ ខណ្ឌសែនសុខ និង (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ចាប់ពីសង្កាត់ច្បារអំពៅ១ រហូតដល់សង្កាត់ព្រែកឯង ក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីរុះរើគន្លងខ្សែបណ្តាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវជាតិលេខ6A ផ្លូវជាតិលេខ៥ និងផ្លូវកោះនរា ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៤

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

**គិច_អ៊ិច**

អគ្គិសនីកម្ពុជា : # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១ ទូរសារ : (៨៥៥) ២៣ ៤២៦ ០១៨